អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃ២៨ខែ មករា ឆ្នាំ ២០១០

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំពេញអង្គលើកទី៧ របស់ អវតក នៅថ្ងៃអង្គារ៍ ទី២ ខែកុម្ភៈ ឆ្នាំ២០១០

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) នឹងរៀបចំកិច្ចប្រជុំពេញអង្គលើកទី៧ របស់ខ្លួនចាប់ពីថ្ងៃអង្គារ៍ ទី២ ដល់ទី១០ ខែកុម្ភៈ ឆ្នាំ២០១០ នៅបន្ទប់សវនាការធំនៅក្នុងបរិវេណ អតវក។

អ្នកសារព័ត៌មានបានទទួលការអញ្ជើញឲ្យចូលរួមនៅក្នុងពិធីបើកកិច្ចប្រជុំពេញអង្គនេះ ដែល នឹងចាប់ផ្តើមពីម៉ោង ៩ ព្រឹក ថ្ងៃអង្គារ៍ ទី២ ខែកុម្ភៈ នៅបន្ទប់សវនាការធំនៅក្នុងបរិវេណ អតវក។ ឯកឧត្តម គង់ ស្រ៊ឹម ប្រធានកិច្ចប្រជុំពេញអង្គ និងអនុប្រធានពេញអង្គ ចៅក្រម Silvia Cartwright នឹងថ្លែងសុន្ទរកថាបើកនាឱកាសនោះ។

អ្នកសារព័ត៌មានក៏បានទទួលការអញ្ជើញឲ្យចូលរួមសង្កេតការណ៍ក្នុងពិធីសច្ចាប្រណិធានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក Andrew Cayley និងសហព្រះរាជអាជ្ញារងអន្តរជាតិ លោក Nicholas Koumjian ដែលនឹងប្រព្រឹត្តទៅភ្លាម បន្ទាប់ពីការបញ្ចប់ការថ្លែងសន្ទរកថាបើក អង្គប្រជុំ។

កិច្ចប្រជុំពេញអង្គនឹងពិភាក្សាទៅលើការធ្វើវិសោធនកម្មមួយមួយចំនួនលើវិធានផ្ទៃក្នុងពាក់ព័ន្ធ នឹងការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការនីតិវិធីរបស់ អវតក។ ដោយសារ តែមានការដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនសម្រាប់សំណុំរឿង ០០២ និងភាពស្មុគ ស្មាញនៃសំណុំរឿង អវតក ចាំបាច់ត្រូវរៀបចំដើមបណ្តឹងរដ្ឋប្បវេណីជាក្រុម មុននឹងចាប់ផ្តើមសវនាការ។ ការរៀបចំដូច្នេះនឹងធានាថា អវតក នឹងមានលទ្ធភាពចេញសាលក្រមមួយសម្រាប់ សំណុំរឿងសំខាន់របស់ខ្លួន និងការធ្វើឲ្យជនរងគ្រោះយល់ថា ខ្លួនពិតជាបានចូលរួមក្នុងដំណើរការ នីតិវិធី។

កិច្ចប្រជុំពេញអង្គកាលពីខែកញ្ញា ឆ្នាំ២០០៩ បានឯកភាពថា នៅដំណាក់កាលដំណើរការ សវនាការ និងការប្តឹងឧទ្ធរណ៍ នឹងមានការរៀបចំឲ្យចេញជាបណ្តឹងទាមទារសំណងផ្លូវចិត្ត និងសមូហភាព តែមួយដែលតំណាងឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានចងកក្រងជា ក្រុមតែមួយ។ ក្រុមនេះនឹងមានសហមេធាវីនាំមុខតំណាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលមានការគាំទ្រពីមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី។ កិច្ចប្រជុំពេញអង្គនេះក៏នឹងសម្រេចអនុម័តទម្រង់ បន្ថែមផ្សេងទៀតនៃការចូលរួមរបស់ជនរងគ្រោះដែលនឹងកើតមានខាងក្រៅដំណើរការនីតិវិធីផ្លូវការនៃអង្គជំនុំជម្រះ។

សំណើសុំធ្វើវិសោធនកម្មវិធានមួយចំនួនសម្រាប់ពិភាក្សាសម្រេចក្នុងកិច្ចប្រជុំពេញអង្គលើកទី៧ ត្រូវបានពិភាក្សាជាដំបូងដោយ អនុគណៈកម្មាធិការដែលមានភារកិច្ចផ្តល់អនុភាពទៅលើសេចក្តី សម្រេចផ្សេងៗរបស់កិច្ចប្រជុំពេញអង្គកាលពីខែកញ្ញា ឆ្នាំ២០០៩ ហើយបន្ទាប់មកសំណើធ្វើ វិសោធនកម្មទាំងនេះត្រូវបានកែសម្រួលបន្ថែមទៀតដោយគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង ដែលបានទទួលយោបល់ទៅលើសំណើវិសោធនកម្មពី អង្គការសង្គមស៊ីវិល មេធាវីភាគីដើមបណ្តឹង បណ្តឹងរដ្ឋប្បវេណី អង្គភាពជនរងគ្រោះ ការិយាល័យសហព្រះរាជអាជ្ញា និងអង្គភាពគាំពារការ ការពារក្តី។

សំណើសុំធ្វើវិសោធនកម្មវិធានមួយទៀតនៅកិច្ចប្រជុំពេញអង្គលើកទី ៧ គឺការរៀបចំឲ្យមាន សហមេធាវីនាំមុខឯករាជ្យ ដែលមានអំណាចដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង និងមានការទទួលខុស ត្រូវទាំងស្រុងចំពោះការតស៊ូមតិទូទៅ យុទ្ធសាស្ត្រ និងការបកស្រាយក្នុងពេលសវនាការដែលជា ប្រយោជន៍ដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានចងក្រងជាក្រុម នៅពេលសវនាការ និងពេលផ្សេងទៀត។ នៅក្នុងការទទួលខុសត្រូវនេះ សហមេធាវីនាំមុខបានទទួលការគាំទ្រពីមេធាវីភាគីដើម បណ្តឹងរដ្ឋប្បវេណី ដែលតំណាងឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬក្រុមភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ការគាំទ្រនេះអាចពង្រីករហូតដល់រួមទាំងការផ្តល់សារណាផ្ទាល់មាត់ ឬសារណាលាយលក្ខណ៍អក្សរ និងការពិនិត្យទៅលើកូនក្តី និងសាក្សី។ ការរៀបចំបែបនេះបង្ហាញថា ការធ្វើសក្ខីកម្មរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចថានឹងនៅតែជាផ្នែកមួយយ៉ាងសំខាន់នៃការជំនុំជម្រះសំណុំរឿង០០២។ ការ ផ្តល់ជំនួយថវិកា និងរដ្ឋបាលដើម្បីបង្កើនតំណាងផ្លូវច្បាប់សម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដោយ ប្រើប្រាស់ថវិកាពីអង្គជំនុំជម្រះ ក៏ត្រូវបានស្នើសុំដែរ។

ការអនុម័តលើសំណើនេះនឹងអាចត្រួសត្រាយ ផ្លូវក្នុងការបង្កើតកម្មវិធីជំនួយផ្លូវច្បាប់សម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ជាការរំពឹងទុក ការធ្វើ បែបនេះអាចពង្រឹងការចូលរួមប្រកបដោយអត្ថន័យរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំ រឿង០០២។ សំណើវិសោធនកម្មវិធានផ្សេងទៀតមានទិសដៅរៀបចំបណ្តឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី ឲ្យទៅជាសារណារបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានចងក្រងជាក្រុមតែមួយ ឬច្រើនជាងមួយ បើសិនជាការពន្យល់ដោយមានសំអាងហេតុច្បាស់លាស់។

សំណើវិសោធនកម្មវិធានវិធានក៏រួមមានបទប្បញ្ញត្តិមួយចំនួនដែលជួយពង្រឹងសមត្ថភាព អង្គភាពការពារជនរងគ្រោះក្នុងការបង្កើតកម្មវិធីសម្រាប់ជនរងគ្រោះ និងវិធានការផ្លូវច្បាប់ផ្សេង ទៀត។ វិធានការបែបបនេះអាចរួមមានសេវាកម្មផ្សេងៗជាច្រើន និងការបញ្ចូលជនរងគ្រោះពីគ្រប់ ទិសទីឲ្យបានច្រើន លើសពីចំនួនជនរងគ្រោះតិចតួចដែលអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងរបស់ អវតក។

នៅចុងបញ្ចប់នៃកិច្ចប្រជុំពេញអង្គ អវតក នឹងចេញសេចក្តីប្រកាសព័ត៌មានមួយទៀតនៅថ្ងៃ អង្គារ៍ ទី៩ ខែកុម្ភៈ ឆ្នាំ២០១០។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង


លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោក **ឌីម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 0៩៤
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី **យូកូ មេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិច maeday@un.org